ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

**សភាព្រហ្មទណ្ឌ**
**សំណុំរឿងព្រហ្មទណ្ឌ**
លេខ ១២២
ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២២
**សាលដីកា**
លេខ ៤០៣ "VI"
ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២

# សាលដីកា

## នាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២២
ដោយមានសមាសភាពនៃក្រុមប្រឹក្សាជំនុំជម្រះ៖

១-ឯកឧត្តម [redacted] ជាប្រធាន
២-ឯកឧត្តម [redacted] ជាចៅក្រម
៣-ឯកឧត្តម [redacted] ជាចៅក្រម
៤-ឯកឧត្តម [redacted] ជាចៅក្រម
៥-លោកជំទាវ [redacted] ជាចៅក្រម

**ចៅក្រមរបាយការណ៍**

ឯកឧត្តម [redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] ព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ៣៨៨ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] ទ៉ា ដែលបានប្តឹងសាទុក្ខចំពោះសាលដីកាព្រហ្មទណ្ឌលេខ ១២២ ក្រVI.ភ.ស ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន ៖

-**ជនជាប់ចោទឈ្មោ**[redacted]**ទ៉ា ហៅ តឿ** ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរជាងឈើ ទីកន្លែងកំណើត សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួននៅផ្ទះ [redacted] ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ខេង (រ)


មហាវិថី សម្តេចសុធារស, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, កម្ពុជា Sothearos Blvd, Sangkat Chatomuk, Khan Daun Penh, Cambodia
Scanned with CamScanner

ម្ដាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ ជានីតិជន ទោសពីមុនគ្មាន ។

**"អ្នកប្ដឹងសាទុក្ខ"**

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៨៤៩០ (យ) ង.យ.ង ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០២០ ។

-មានមេធាវី [redacted] **មូរ៉ា** ជាអ្នកការពារសិទ្ធិ។

**-ជនជាប់ចោទពីបទ ដឹកជញ្ជូន ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខសាខាពន្ធដារ ខណ្ឌចំការមន ផ្លូវលេខ ៤៤៨ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

**I-អំពីអង្គហេតុ**

កាលពីថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០២០ នៅវេលាម៉ោង ១៦ និង ៥០នាទី កំលាំងសមត្ថកិច្ចនៃមន្ទីរប្រឆាំងគ្រឿងញៀន បានចុះបង្ក្រាបជាក់ស្ដែងករណីគ្រឿងញៀន នៅចំណុចមុខសាខាពន្ធដារ ខណ្ឌចំការមន ផ្លូវលេខ ៤៤៨ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ដោយបានឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted]រ៉ា ហៅ តឿ ខណៈពេលកំពុងជិះម៉ូតូយកថ្នាំញៀនឱ្យម៉ូយ និងបានដកហូតក្រាមពណ៌សថ្លាចំនួន ០២ កញ្ចប់ ទម្ងន់ ១៩,៣២ ក្រាម គ្រឿងញៀននេះបានយកពីឈ្មោះ **អាហ្វា** ភេទប្រុស អាយុ ៣២ឆ្នាំ និងឈ្មោះ **អាទី** ភេទប្រុស អាយុប្រហែល ២៧ឆ្នាំ ជាមេក្លោងលក់គ្រឿងញៀន ។

**II-សេចក្ដីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញ និងសាលាឧទ្ធរណ៍ភ្នំពេញ**

-**បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ **២២ "ហ" ក្រ៣** ចុះថ្ងៃទី **១២ ខែមករា ឆ្នាំ២០២១** របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១-ផ្ដន្ទាទោសលើឈ្មោះ [redacted]រ៉ា ហៅ តឿ ភេទប្រុស អាយុ ៣១ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន) រៀល ពីបទ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចមុខសាខាពន្ធដារខណ្ឌចំការមន ផ្លូវលេខ ៤៤៨ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៥ និងមាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-វត្ថុចាប់យក ៖

ក-ថ្នាំញៀនចំនួន ១៧,៣២ (ដប់ប្រាំពីរក្បៀសសាមសិបពីរ) ក្រាម សម្រេចរឹបអូសបំផ្លាញចោល ។

ខ-ម៉ូតូចំនួន ០១គ្រឿង ម៉ាក HONDA VISION ពណ៌ក្រហម ពាក់ស្លាកលេខកំពង់ចាម ១Q-១៧៨៣ សម្រេចរឹបអូស ។

Scanned with CamScanner

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ០៥ ខែមករា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ១២ ខែមករា ឆ្នាំ២០២១ ។

បើកផ្លូវឱ្យប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

*-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ១០៦ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ* [redacted] *រ៉ា ហៅ តឿ ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ២២ "ហ" ក្រ៣ ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល។*

-**បានឃើញ** សាលដីកាព្រហ្មទណ្ឌលេខ ១២២ ក្រVI.ភ.ស ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ១០៦ ចុះថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០២១ របស់ជនជាប់ចោទ ឈ្មោះ [redacted] រ៉ា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២២ "ហ" ក្រ៣ ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោ [redacted] រ៉ា តាមនីតិវិធីច្បាប់ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ ។

បើកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

*-បានឃើញ បណ្តឹងសាទុក្ខលេខ៣៨៨ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ* [redacted] *រ៉ា ហៅ តឿ បានប្តឹងចំពោះសាលដីកាព្រហ្មទណ្ឌលេខ ១២២ ក្រVI.ភ.ស ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។*

## III-តុលាការកំពូល
## នាពេលសវនាការ

-ចៅក្រម អានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំឱ្យ តាមចម្លើយជនជាប់ចោទ ឈ្មោះ [redacted] រ៉ា ហៅ តឿ ព្រមទាំងវត្ថុតាងចាប់យកដាក់ស្តែងនានា បង្ហាញថាជនជាប់ចោទ ពិតជាបាន ប្រព្រឹត្តអំពើជួញដូរនិងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន ។ សាលដីកាព្រហ្មទណ្ឌលេខ ១២២ ក្រVI .ភ.ស ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ សម្រេចត្រឹមត្រូវតាម

Scanned with CamScanner

ច្បាប់។ ជនជាប់ចោទឈ្មោះ [redacted] រ៉ា ហៅ តឿ ជាដើមបណ្តឹងសាទុក្ខ ពុំបានដាក់សារណាការពារជូនតុលាការកំពូលតាមកំណត់ច្បាប់ឡើង។ គប្បីក្រុមប្រឹក្សា ពិចារណាសម្រេចច្បាប់។

ហេតុដូច្នេះ តំណាងមហាអយ្យការ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចតម្កល់សាលដីកាព្រហ្មទណ្ឌ លេខ ១២២ ក្រVI .ភ.ស ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការដដែល ។

-ជនជាប់ចោទឈ្មោះ [redacted]រ៉ា ហៅ តឿ បានឆ្លើយថា ខ្លួនសុំឱ្យក្រុមប្រឹក្សាជួយបន្ធូបន្ថយទោស និងធ្វើជាមនុស្សល្អ ពេលត្រឡប់ទៅវិញ ។

<u>សំណូមពរ</u> ស្នើសុំឱ្យប្រធានក្រុមប្រឹក្សាជួយបន្ធូបន្ថយទោសដល់ខ្លួន

-មេធាវី [redacted]បូរ៉ា ជាអ្នកការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]រ៉ា ធ្វើសេចក្តីសន្និដ្ឋានថា តាមមាត្រា៣២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចែងមិនឱ្យប្រើស្ថានសម្រាលក្នុងមាត្រា៩៣ នៃក្រមព្រហ្មទណ្ឌ។ តាមអង្គហេតុខាងលើក៏ដូចជាចម្លើយរបស់កូនក្តីខ្លួនដែលមានលក្ខណៈស៊ីសង្វាក់ ពាក់ព័ន្ធនិងមូលហេតុនៃការប្រព្រឹត្ត (សារភាពថាបានប្រព្រឹត្ត តែមិនមែនជួញដូរទេ ការប្រព្រឹត្តនេះដើម្បីជីវភាពចង់បានលុយព្យាបាលជំងឺកូន គាត់ដឹងខុស បានកែខ្លួននៅក្នុងពន្ធ និងថែមទាំងសន្យាថាលែងប្រព្រឹត្តល្មើសទៀតហើយ) ជាកត្តាមួយចំនួន មិនស្ថិតក្នុងមាត្រា៩៣ នៃក្រមព្រហ្មទណ្ឌ ហើយមាត្រា៣២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មិនហាមការសម្រាលទោសផ្អែកលើកត្តាទាំងនេះទេ។ ក្នុងន័យនេះ កូនក្តីខ្លួននៅតែទទួលបានការសម្រាលទោស សម្រាលរហូតក្រោមអប្បបរមា។ សាលដីកា មិនបានបង្ហាញជាក់លាក់នូវមូលហេតុ និងឆ្លើយតបនិងអ្វីដែលកូនក្តីខ្លួនលើកឡើង ក្រៅពីការលើកជាដដែលនូវសំអាងហេតុសាលក្រមសាលាដំបូង។ ភាពមិនច្បាស់លាស់ មិនឆ្លើយតបនេះធ្វើឱ្យកូនក្តីខ្លួនមិនអស់ចិត្ត ទើបប្តឹងសាទុក្ខ។ មូលហេតុនេះ ស្ថិតចូលចំណុចក្នុងមាត្រា៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលតុលាការកំពូល អាចទទួលយកបណ្តឹងនេះ មកពិនិត្យបាន។ សំអាងហេតុ និងសេចក្តីសន្និដ្ឋានអំពីទម្រង់នៃការចូលរួមរបស់កូនខ្លួនមិនត្រឹមត្រូវទេ អង្គហេតុមិនមែនជាការជួញដូរទេ ពីព្រោះ កូនក្តីខ្លួនទៅយកសាធាតុញៀនតាមបញ្ជារបស់ឈ្មោះទី ជាមេក្លោងជួញដូរ។ ដូចនេះ មិនមានធាតុផ្សំសំភារៈ នៃបទជួញដូរសាធាតុញៀនក្នុងមាត្រា៤០។ អង្គហេតុដែលឯកភាព គួជាបទសមគំនិតជួញដូរ ដែលអាចនិងទោសទទួលតិចជាងចារី។ កូនក្តីខ្លួនគ្រាន់តែដឹកជញ្ជូនបានឈ្នួល ត្រូវទទួលទោស៥ឆ្នាំ ពិន័យ១០លាន និងរឹមអូសម៉ូតូ ដែលគាត់ខ្ចីមិត្តភ័ក្រ។ សំអាងហេតុមិនគ្រប់គ្រាន់ អាចប៉ះដល់កម្រិតទោស។ តុលាការកំពូលអាចគ្រាន់តែបង្វិល ជាមួយការណែនាំនូវមូលដ្ឋានច្បាប់រឹងមាំ ដើម្បីឱ្យសាលាឧទ្ធរណ៍ពិចារណាជាថ្មី។

<u>សុំណូមពរ</u> ស្នើសុំក្រុមប្រឹក្សាមេត្តាសម្រេច សុំបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍ដើម្បីពិចារណាអំពីទោសឡើងវិញ។



Scanned with CamScanner

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៨៨ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ [redacted] ហៅ គឿ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា៤១៧ មាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ជនជាប់ចោទឈ្មោះ[redacted] ហៅ គឿ ពិតជាបានប្រព្រឹត្តបទល្មើសដូចបានចោទប្រកាន់ ។ ជនជាប់ចោទឈ្មោះ[redacted] ហៅ គឿ នៅក្នុងមន្ទីរឃុំឃាំង ម១ ត្រូវបានប្រគល់លិខិតជូនដំណឹងឱ្យដាក់សារណាការពារ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ តាមរយៈមន្ត្រីពន្ធនាគារ ម១ ឈ្មោះ[redacted]ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ ដែលជាអ្នកទទួលជំនួស ។ ប៉ុន្តែជនជាប់ចោទពុំបានដាក់សារណាការពារជូនតុលាការកំពូល ដើម្បីពិចារណាសម្រេចលើបញ្ហាច្បាប់ស្របតាមមាត្រា ៤៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ។ នាពេលសវនាការ ជនជាប់ចោទរូបនេះ គ្រាន់តែសុំឱ្យមានការបន្ធូរបន្ថយទោសឱ្យខ្លួនប៉ុណ្ណោះ ដែលការស្នើសុំនេះ ពុំមែនជាបញ្ហាច្បាប់នោះទេ។ ហេតុដូច្នេះ បណ្តឹងសាទុក្ខនេះពុំមានមូលដ្ឋានច្បាប់ ។ តុលាការកំពូលគប្បីសម្រេចបដិសេធបណ្តឹងសាទុក្ខរបស់ជនជាប់ចោទរូបនេះ ។

៣-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១២២ ក្រVI.ភ.ស ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ហើយ ។

## ហេតុដូច្នេះ សម្រេច៖

១-បដិសេធ បណ្តឹងសាទុក្ខលេខ ៣៨៨ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ របស់ជនជាប់ចោទឈ្មោះ[redacted] ភ៉ា ហៅ គឿ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១២២ ក្រVI.ភ.ស ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការពេញទាំងមូល។

Scanned with CamScanner

*សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២២ ។*

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ជាប្រធាន |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| លោកជំទាវ | [redacted] | ជាចៅក្រម |
| លោកស្រី | [redacted] | ក្រឡាបញ្ជី |

---

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ ។

ថ្ងៃ អង្គារ ៣ រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ថ្ងៃ អង្គារ ៣ រោច ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២២

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner